# សេចក្តីថ្លែងការណ៍រួម

## ស្តារស្ថានភាពសិទ្ធិមនុស្សឡើងវិញនៅមុនពេលបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២១

យើងខ្ញុំជាអង្គការសង្គមស៊ីវិល សហជីព សមាគម និងសហគមន៍ដូចមានរាយនាមខាងក្រោម មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការវិវឌ្ឍន៍នាពេលថ្មីៗនេះ ចំពោះបំណងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ខណៈដែលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានៅតែប្រឈមជាបន្តបន្ទាប់។ ទោះបីជាស្ថាប័នសិទ្ធិមនុស្សជាតិមានភាពចាំបាច់ខ្លាំងនៅប្រទេសកម្ពុជាយ៉ាងណាក្តី ប៉ុន្តែបើបង្កើតស្ថាប័ននោះឡើងក្នុងបរិយាកាសបែបនេះ នឹងបង្កើនការព្រួយបារម្ភយ៉ាងខ្លាំងជុំវិញប្រសិទ្ធភាពនិងទំនុកចិត្តនៃស្ថាប័ននេះ។ យើងខ្ញុំស្នើឱ្យរដ្ឋាភិបាលផ្តល់អាទិភាពលើការស្តារស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាឡើងវិញជាមុនសិន មុនពេលដែលបង្កើតស្ថាប័ននេះឡើងដើម្បីធានាថាការបង្កើតស្ថាប័ននេះនឹងផ្តល់អត្ថប្រយោជន៍ពិតប្រាកដក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាជាងការបង្កើតឡើងដើម្បីគ្រាន់តែបំពេញទៅតាមការអះអាងប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនាពេលកន្លងមកប៉ុណ្ណោះ។

នៅពេលបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ត្រូវមានការពិចារណាឱ្យបានហ្មត់ចត់ទៅតាមគោលការណ៍ទីក្រុងប៉ារីស ដែលធានាជាស្តង់ដារអប្បបរមាអន្តរជាតិក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។ ចំណុចសំខាន់បំផុតនោះគឺលក្ខខណ្ឌនៃឯករាជ្យភាពពីរដ្ឋាភិបាល។ ប៉ុន្តែ គួរឱ្យស្តាយដែលនាពេលកន្លងមក មានការបង្កើតស្ថាប័នឯករាជ្យជាច្រើន តែទីបំផុតស្ថាប័នទាំងអស់នោះអសកម្ម ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលទាំងស្រុង ដែលនេះធ្វើឱ្យយើងខ្ញុំបារម្ភថាស្ថាប័នសិទ្ធិមនុស្សជាតិដែលនឹងបង្កើតឡើងនោះក៏មិនខុសពីស្ថាប័នមុនៗទាំងនោះដែរ។

ក្នុងពេលដែលបរិយាកាសសិទ្ធិមនុស្សនៅតែប្រឈមនោះ កាន់តែធ្វើឱ្យមានការព្រួយបារម្ភថាការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនៅពេលនេះ អាចនឹងមិនបំពេញតាមគោលបំណងនៃស្ថាប័ននេះចំពោះការការពារនិងការលើកកម្ពស់សិទ្ធិមនុស្ស។ នៅឆ្នាំ២០២១ នេះ ក៏មិនខុសគ្នានឹងឆ្នាំមុនៗដែរ ស្ថានភាពសិទ្ធិមនុស្សមានសភាពធ្លាក់ចុះ និងកាន់តែប្រឈមថែមទៀតដោយសារការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩។ ទោះយ៉ាងណាក្តី រដ្ឋាភិបាលនៅតែបន្តដាក់កំហិតដ៏តឹងរ៉ឹងទៅលើសេរីភាពមូលដ្ឋាន។ លំហសេរីភាពរបស់ពលរដ្ឋបន្តរួមតូចទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយអាជ្ញាធរបាននឹងកំពុងប្រើប្រាស់វិធានការជាច្រើនដើម្បីគាបសង្កត់ទៅលើសំឡេងរិះគន់ ក្នុងនោះរួមទាំងការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីយាយីទៅលើអ្នកការពារសិទ្ធិមនុស្ស សមាជិកគណបក្សជំទាស់ អ្នកសារព័ត៌មានឯករាជ្យ និងអ្នកមានសំឡេងជំទាស់ផ្សេងៗទៀត។ លើសពីនេះ ការអនុម័តច្បាប់មួយចំនួនដែលមានលក្ខណៈគាប

សង្កត់ និងការធ្វើវិសោធនកម្មលើច្បាប់ជាធរមានមួយចំនួនបង្ហាញពីនិន្នាការរបស់រដ្ឋាភិបាលដែលផ្តោតទៅលើអំណាចរបស់ខ្លួន ជាជាងផលប្រយោជន៍ និងសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ។

យើងខ្ញុំទទួលស្គាល់ថាស្ថាប័នសិទ្ធិមនុស្សជាតិពិតជាមានសារៈសំខាន់ ក្នុងការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ប៉ុន្តែ យើងខ្ញុំពិតជាគ្មានទំនុកចិត្តថាស្ថាប័នសិទ្ធិមនុស្សជាតិដែលរដ្ឋាភិបាលនឹងបង្កើតឡើងនេះនឹងមានឯករាជ្យ ប្រសិទ្ធភាពនិងគួរឱ្យទុកចិត្តបាននោះទេ។ ផ្ទុយមកវិញ យើងខ្ញុំមានការព្រួយបារម្ភថាការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនៅក្នុងបរិបទបច្ចុប្បន្ននេះ គឺគ្រាន់តែជាវិធីសាស្ត្រទំនាក់ទំនងសាធារណៈដើម្បីបញ្ឈប់ការរិះគន់ ពីមជ្ឈដ្ឋានអន្តរជាតិទៅលើរដ្ឋាភិបាលក្នុងការគោរពសិទ្ធិមនុស្សតែប៉ុណ្ណោះ។

មុនឈានទៅដល់ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ យើងខ្ញុំស្នើឱ្យរដ្ឋាភិបាលស្តារស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាឡើងវិញ និងបង្កើតបរិយាកាសអំណោយផលសម្រាប់ការបំពេញមុខងារនៃស្ថាប័ននេះប្រកបដោយត្រឹមត្រូវ និងឯករាជ្យភាព។ ជាពិសេស យើងខ្ញុំស្នើឱ្យរដ្ឋាភិបាលបើកលំហសេរីភាពឡើងវិញ និងធានាថាប្រជាពលរដ្ឋគ្រប់រូបអាចអនុវត្តសេរីភាពមូលដ្ឋានដោយសេរីក្នុងនោះរួមទាំង សំឡេងជំទាស់ ព្រមទាំងដោះលែងអ្នកទោសមនសិការទាំងអស់ជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ ព្រមទាំងបង្កើតប្រព័ន្ធតុលាការមួយដែលមានឯករាជ្យពិតប្រាកដ ហើយនិរាករណ៍ ឬធ្វើវិសោធនកម្មច្បាប់ទាំងឡាយណាដែលមានលក្ខណៈគាបសង្កត់ ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ បញ្ឈប់ការបង្ក្រាបលើអ្នកការពារសិទ្ធិមនុស្ស ថ្នាក់ដឹកនាំសហជីព សមាជិកគណបក្សជំទាស់ អ្នកសារព័ត៌មានឯករាជ្យ និងសំឡេងជំទាស់ផ្សេងៗទៀត ហើយធានាឱ្យមានលំហសម្រាប់ការចូលរួមប្រកួតប្រជែងនយោបាយដោយស្មើភាពនៅមុនការបោះឆ្នោតនាពេលខាងមុខនេះ។

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ មានរាយនាមដូចខាងក្រោម:**

1. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
2. អាកស៊ិនអេដ កម្ពុជា
3. អង្គការក្រុមកាងារដើម្បីដោះស្រាយទំនាស់ (កដទ)
4. សហគមន៍អមលាំង (កំពង់ស្ពឺ)
5. សហគមន៍ដីធ្លីអណ្តូងត្របែក
6. សហគមន៍បឹងប្រាំ (បាត់ដំបង)
7. សហព័ន្ធសហជីពកម្មករសំណង់ និង ព្រៃឈើ កម្ពុជា
8. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
9. សមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា
10. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)

11 សម្ព័ន្ធសហជីពកម្ពុជា

12 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

13 មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

14 សហព័ន្ធសហជីពកម្មករចំណីអាហារ និង សេវាកម្ម កម្ពុជា

15 សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)

16 សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ

17 សមាគមកាម្មករកម្ពុជាសេដ្ឋកិច្ច ក្រៅប្រព័ន្ធ

18 សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)

19 វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា

20 សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

21 អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិនុស្ស លីកាដូ

22 សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា

23 សមាគម បណ្តាញយុវជនកម្ពុជា (ប.យ.ក)

24 សមាគមម ន្ត្រីរាជការឯករាជកម្ពុជា (ស៊ីកា)

25 មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (សង់ត្រាល់)

26 សហគមន៍ដីធ្លីដីខក្រោម (កោះកុង)

27 សហគមន៍ដីធ្លីដីខលើ (កោះកុង)

28 សហគមន៍ជាំក្រវៀន (ត្បូងឃ្មុំ)

29 សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម

30 សម្ព័ន្ធសហគមន៍កសិករកម្ពុជា

31 សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (ស.ស.គ)

32 គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)

33 មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

34 សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)

35 សហភាពចលនាកម្មករកម្ពុជា (CCW)

36 សហគមន៍ដក់ពរ (កំពង់ស្ពឺ)

37 សហពន្ធ័សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)

38 សហព័ន្ធសហជីព សេរី ឯករាជ្យ
39 សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
40 សហព័ន្ធសហជីពឯករាជ្យ
41 សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
42 សហគមន៍នេសាទកោះស្រឡៅ (កោះកុង)
43 សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
44 សហជីព ទ្រ ទ្រង់សិទ្ធិបុគ្គលិក កម្មករ និងយោជិត នៃក្រុមហ៊ុនណាហ្គាវើលដ៍
45 សហគមន៍ដីធ្លីខេត្តប៉ៃលិន
46 សហគមន៍ឡពាង (កំពង់ឆ្នាំង)
47 សហគមន៍អូរវល្លិ៍ព្រេង (បាត់ដំបង)
48 សហគមន៍ពាមរស់ (កំពង់ស្ពឺ)
49 មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (ភីឌីភី)
50 សហគមន៍ភ្នំក្រោម (សៀមរាប)
51 អង្គការពន្លកខ្មែរ
52 សហគមន៍ព្រៃឡង់ (ស្ទឹងត្រែង)
53 សហគមន៍ដីធ្លីព្រៃពាយ (កំពត)
54 សហគមន៍ស្មើសាមគ្គី (កំពង់ស្ពឺ)
55 អង្គការសមាគមជាងត្នោត
56 សហភាពផ្ទះសាមគ្គី
57 សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
58 សហគមន៍ដីធ្លីតានូន (កោះកុង)
59 អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ស.គ.ក)
60 សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
61 អង្គការអភិវឌ្ឍន៍ធនធានយុវជន (កអធយ)